ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

L.Y.P GROUP CO.,LTD
ក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប
L.Y.P GROUP CO., LTD

ខុទ្ទកាល័យ
ចូល
លេខ: ៤០១៣
ថ្ងៃទី: ០១.០៩.២២
ម៉ោង:

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ ៖** ករណីសំណើសុំកំណត់កំពង់ផែ **ក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប** (L.Y.P GROUP CO., LTD) ដែលមានទីតាំងនៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង សម្រាប់នាវានេសាទ ឬនាវាពាក់ព័ន្ធនឹងការនេសាទបរទេសចូលចត ឡើងផល ផលិតផលជលផល និងប្រើសេវាកំពង់ផែ។

**យោង ៖** លិខិតលេខ៨០៦៥ កសក ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០២២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការលើកស្ទួយសេដ្ឋកិច្ចជាតិ និងអនុវត្តកិច្ចព្រមព្រៀង ស្ដីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត របស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ ដែលព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិក។

ចំពោះករណីនេះ ខ្ញុំសូមឯកភាព និងគាំទ្រការស្នើសុំកំណត់យក កំពង់ផែ **ក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប** (L.Y.P GROUP CO., LTD) សម្រាប់នាវានេសាទ ឬនាវាពាក់ព័ន្ធនឹងការនេសាទបរទេស ចូលចត ឡើងផល ផលិតផលជលផល និងប្រើសេវាកំពង់ផែ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពរាប់អានអំពីខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២

**ប្រធានក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប**

**L.Y.P GROUP CO., LTD**

ព្រះរាជាណាចក្រកម្ពុជា
អិល.វ៉ាយ.ភី គ្រុប
L. Y. P. GROUP CO., LTD
ស្នាក់ការខេត្តកោះកុង

**អ្នកឧកញ៉ា.លី_យ៉ុងផាត់**

**ចម្លងជូន៖**
- រដ្ឋបាលខេត្តកោះកុង
- រដ្ឋបាលជលផល
  "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ

02/09/2022